ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ស្តង់ដា
# ផ្ទះស្នាក់កម្ពុជា



ឆ្នាំ ២០២២


រៀបចំដោយ៖ នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍

គាំទ្រដោយ៖ គម្រោងទេសចរណ៍ GMS TIIG II No. 3701-CAM (COL)

## សារលិខិតរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍
## គាំទ្រស្តង់ដាផ្ទះស្នាក់កម្ពុជា

ក្នុងនាមក្រសួងទេសចរណ៍ និងថ្នាក់ដឹកនាំ ខ្ញុំសំដែងការគាំទ្រចំពោះស្តង់ដាផ្ទះស្នាក់កម្ពុជា ។ ស្តង់ដានេះគឺជាឯកសារដ៏សំខាន់សម្រាប់ធ្វើការជ្រើសរើស និងវាយតម្លៃស្តង់ដាផ្ទះស្នាក់សហគមន៍ ស្តង់ដាផ្ទះស្នាក់ជនបទ និងស្តង់ដាផ្ទះស្នាក់ទីក្រុងនៃ **កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ។**

ជាការពិត វិស័យទេសចរណ៍កម្ពុជា បាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ដែលជះឥទ្ធិពលទៅលើសង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាន។ អាស្រ័យលើកត្តាទាំងនេះ ក្រសួងទេសចរណ៍ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលបាននឹងកំពុងបន្តធ្វើកិច្ចការរបស់ខ្លួនយ៉ាងសស្រាក់សស្រាំ ព្រមទាំងពង្រឹងកិច្ចសហការយ៉ាងល្អជាមួយផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការសម្រេចឲ្យបាននូវការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាពនៅកម្ពុជា។ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវរួមចំណែកយ៉ាងសកម្មដល់កិច្ចអភិវឌ្ឍន៍ ថែរក្សា ការពារ អភិរក្ស សម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ និងធនធានធម្មជាតិ ជាពិសេសការរួមចំណែកបន្សាំនឹងការបម្រែបម្រួលអាកាសធាតុជាសកល។

ជាក់ស្តែង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងទេសចរណ៍ បានដាក់ចេញនូវទិសដៅជាយុទ្ធសាស្ត្រដ៏ត្រឹមត្រូវក្នុងការអនុវត្តនៅទូទាំងប្រទេសស្របតាមនិន្នាការបច្ចុប្បន្ននៃសកលលោក ជាពិសេសទស្សនទានបៃតង ភាពស្រស់បំព្រងនៃធម្មជាតិ ការគិតគូរ និងការទទួលខុសត្រូវខ្ពស់លើបញ្ហាបរិស្ថាន និងសង្គម។ ទាំងអស់នេះត្រូវបានបង្ហាញ និងកំណត់យ៉ាងច្បាស់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ និងចលនាប្រលងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** ព្រមទាំងផែនទីបង្ហាញផ្លូវឆ្ពោះទៅរកកំណើនបៃតងនៅកម្ពុជា។

ទស្សនទានផ្ទះស្នាក់ ត្រូវបានចាត់ទុកថាជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជនបទនៅតាមប្រទេសជាសមាជិកអាស៊ាន។ កម្មវិធីផ្ទះស្នាក់រួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍តាមរយៈការបង្កើតប្រាក់ចំណូលដោយផ្ទាល់ ការគាំទ្រដល់វប្បធម៌សិល្បៈប្រពៃណី និងមុខរបរសិប្បកម្ម ពិសេសលើកទឹកចិត្តដល់សហគមន៍ក្នុងការបង្កើតឡើងវិញនូវរមណីយដ្ឋានតាមជនបទ រមណីយដ្ឋានប្រវត្តិសាស្ត្រ និងលើកតម្កើងការអភិរក្សអភិវឌ្ឍន៍សម្បត្តិវប្បធម៌ធម្មជាតិ។

ការដាក់ចេញនូវស្តង់ដាផ្ទះស្នាក់កម្ពុជា ដើម្បីជម្រុញឲ្យប្រជាជននៅតាមសហគមន៍ជនបទ និងទីក្រុងទទួលបាននូវគោលការណ៍ណែនាំច្បាស់លាស់ស្តីពីការរៀបចំអភិវឌ្ឍន៍ផ្ទះស្នាក់របស់ខ្លួនស្របតាមស្តង់ដាធានាបាននូវការផ្តល់សេវាផ្ទះស្នាក់ប្រកបដោយគុណភាព គុណតម្លៃ និងសុវត្ថិភាពដល់ភ្ញៀវទេសចរ។

ជាទីបញ្ចប់ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ឯកសារស្តង់ដានេះនឹងរួមចំណែកក្នុងការពង្រឹងគុណភាពផលិតផលទេសចរណ៍ស្របពេលដែលកម្ពុជាកំពុងអភិវឌ្ឍន៍ទៅជាគោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិលំដាប់ពិភពលោកប្រកបដោយភាពទាក់ទាញ និងនិរន្តរភាពដែលមានឧត្តមភាពខ្ពស់ក្នុងការប្រកួតប្រជែងនៅក្នុងតំបន់ និងពិភពលោក។

**រដ្ឋមន្ត្រី**

**ថោង ខុន**

# មាតិកា


**សារលិខិតរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍** ..... i

I- **សេចក្តីផ្តើម** ..... 1

II- **និយមន័យ** ..... 2

III-**ស្តង់ដាផ្ទះស្នាក់សហគមន៍** ..... 3

តារាងសូចនាករគោលនៃការវាយតម្លៃផ្ទះស្នាក់សហគមន៍ ..... 3

១. សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ ..... 3

២. សូចនាករគោលនៃកន្លែងស្នាក់នៅ ..... 4

៣. សូចនាករគោលនៃទីតាំង ..... 5

៤. សូចនាករគោលនៃអនាម័យ និងភាពស្អាត ..... 5

៥. សូចនាករគោលនៃសកម្មភាពកំសាន្ត ..... 6

៦. សូចនាករគោលនៃសន្តិសុខសុវត្ថិភាព ..... 7

៧. សូចនាករគោលនៃការគ្រប់គ្រង ..... 8

៨. សូចនាករគោលនៃការសិក្សាទីផ្សារ និងផ្សព្វផ្សាយ ..... 9

៩. សូចនាករគោលនៃគោលការណ៍និរន្តភាព ..... 9

IV-**ស្តង់ដាផ្ទះស្នាក់ជនបទ** ..... 11

តារាងសូចនាករគោលនៃការវាយតម្លៃផ្ទះស្នាក់ជនបទ ..... 12

១. សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ ..... 12

២. សូចនាករគោលនៃកន្លែងស្នាក់នៅ ..... 12

៣. សូចនាករគោលនៃទីតាំង ..... 13

៤. សូចនាករគោលនៃអនាម័យ និងភាពស្អាត ..... 13

៥. សូចនាករគោលនៃសកម្មភាពកំសាន្ត ..... 14

៦. សូចនាករគោលនៃសន្តិសុខសុវត្ថិភាព ..... 14

៧. សូចនាករគោលនៃការគ្រប់គ្រង ..... 15

៨. សូចនាករគោលនៃការសិក្សាទីផ្សារ និងផ្សព្វផ្សាយ ..... 15

V- **ស្តង់ដាផ្ទះស្នាក់ទីក្រុង** ..... 16

តារាងសូចនាករនៃការវាយតម្លៃផ្ទះស្នាក់ទីក្រុង ..... 16

១. សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ ..... 16

២. សូចនាករគោលនៃកន្លែងស្នាក់នៅ ..... 17

៣. សូចនាករគោលនៃទីតាំង ..... 18

៤. សូចនាករគោលនៃអនាម័យ និងភាពស្អាត ..... 18

៥. សូចនាករគោលនៃសន្តិសុខសុវត្ថិភាព ..... 19

៦. សូចនាករគោលនៃការផ្សព្វផ្សាយ ..... 20

៧. សូចនាករគោលនៃគោលការណ៍និរន្តរភាព ........................................................................ 20
VI- **យន្តការនៃការវាយតម្លៃស្តង់ដាផ្ទះស្នាក់សហគមន៍ ស្តង់ដាផ្ទះស្នាក់ជនបទ និងស្តង់ដាផ្ទះស្នាក់ទីក្រុង** . 21
VII- **ដំណើរការនៃការប្រឡងប្រណាំង** ........................................................................ 21
**ឧបសម្ព័ន្ធ** ........................................................................ 22
ឧបសម្ព័ន្ធ១ វាក្យស័ព្ទ និងនិយមន័យ ........................................................................ 25
ឧបសម្ព័ន្ធ២ លក្ខខណ្ឌក្នុងការចូលរួមកម្មវិធីស្តង់ដាផ្ទះស្នាក់កម្ពុជា ........................................ 27

# I-សេចក្តីផ្តើម

វិស័យទេសចរណ៍ ដែលមានលក្ខណៈជាប្រព័ន្ធគឺជាវិស័យអាទិភាពមួយត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ វិស័យទេសចរណ៍ រួមចំណែកកសាងសេដ្ឋកិច្ចសង្គម ផ្តល់ឱកាសការងារមុខរបរ ប្រាក់ចំណូលលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ទេសចរណ៍កម្ពុជាត្រូវបានទទួលស្គាល់ថាជា "**មាសបៃតង**" ជាផ្នែកដ៏សំខាន់នៃសេដ្ឋកិច្ចបៃតងដែលចំណូលពីវិស័យនេះត្រូវបានចាក់បញ្ចូលភ្លាមៗទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ រួមចំណែកជំរុញកំណើនផលិតផលក្នុងស្រុកសរុប (GDP) និងធ្វើឲ្យមានលំនឹងផ្នែកជញ្ជីងពាណិជ្ជកម្ម និងចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ។

រាជរដ្ឋាភិបាលកម្ពុជា បានបន្តធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដែលមានការពាក់ព័ន្ធទេសចរណ៍ *(ផ្លូវគោក អាកាសយានដ្ឋាន កំពង់ផែ ទឹកស្អាត អគ្គិសនី ប្រព័ន្ធគ្រប់គ្រងកាកសំណល់ រឹង និងរាវ)* ក៏ដូចជាការផ្តល់នូវបរិយាកាស សុខសន្តិភាព សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងការបង្ករលក្ខណៈងាយស្រួលក្នុងការសម្របសម្រួលលើការដឹកជញ្ជូន និងការធ្វើដំណើររបស់ភ្ញៀវទេសចរការស្នាក់នៅ និងការទស្សនា។ល។ ទន្ទឹមនឹងការធ្វើឲ្យប្រសើរឡើងនេះ ឃើញថា ដោយមានការកើនឡើងជាបន្តបន្ទាប់នូវភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជា ជាក់ស្តែងក្នុងឆ្នាំ២០១៤ មានភ្ញៀវទេសចរប្រមាណ **៤,៥លាននាក់** កើនឡើង**៧%**ធៀបនឹងឆ្នាំ២០១៣ និងនាំមកនូវប្រាក់ចំណូលប្រមាណជាង **៣.០០០លានដុល្លា** បានចាក់បញ្ចូលក្នុងចរន្តសេដ្ឋកិច្ចជាតិ និងបង្កើតនូវឱកាសការងារដោយផ្ទាល់ប្រមាណជាង **៥០ម៉ឺននាក់** និងផ្តល់ការងារដោយប្រយោល**រាប់ម៉ឺននាក់**ទៀត។ ជាមួយនឹងកំណើននេះឃើញថា មានការកើនឡើងនៃនិន្នាការទេសចរណ៍បែបអេកូទេសចរណ៍នៅតាមសហគមន៍ និងទេសចរណ៍បែបជនបទស្រុកស្រែចំការដែលទាំងនេះតម្រូវឲ្យមានការរៀបចំសម្បទារទេសចរណ៍គ្រប់គ្រាន់ និងមានគុណភាពតាមកម្រិតស្តង់ដាដើម្បីទទួលភ្ញៀវទេសចរ។

កម្មវិធីផ្ទះស្នាក់ ជាទំរង់មួយនៃវិស័យទេសចរណ៍ដែលផ្តល់ឱកាសឲ្យភ្ញៀវទេសចរទទួលបាននូវបទពិសោធន៍អំពីរបៀបរស់នៅតាមភូមិជាមួយសហគមន៍នៅជនបទ។ ថ្វីត្បិតការទទួលបានបទពិសោធន៍ពីធម្មជាតិ និងសហគមន៍ កំពុងមានប្រជាប្រិយភាពកាន់តែខ្លាំងឡើងជាមួយនឹងភ្ញៀវជនជាតិបរទេស កម្មវិធីផ្ទះស្នាក់គួររក្សាឲ្យមានលក្ខណៈជាទ្រង់ទ្រាយតូច ពិសេសផ្ទះស្នាក់គួរជាកម្មសិទ្ធិរបស់សហគមន៍ និងប្រតិបត្តិដោយសហគមន៍ផ្ទាល់ដើម្បីបំរើឲ្យផលប្រយោជន៍សេដ្ឋកិច្ចទៅដល់សហគមន៍ផ្ទាល់។

បើតាមទំរង់ទេសចរណ៍សហគមន៍វិញ ទស្សនទានផ្ទះស្នាក់ត្រូវបានចាត់ទុកថាជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជនបទនៅតាមប្រទេសជាសមាជិកអាស៊ាន។ កម្មវិធីផ្ទះស្នាក់រួមចំណែកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍តាមរយៈការបង្កើតប្រាក់ចំណូលដោយផ្ទាល់ ការគាំទ្រដល់វប្បធម៌ សិល្បៈប្រពៃណី និងមុខរបរសិប្បកម្ម ពិសេសលើកទឹកចិត្តដល់សហគមន៍ក្នុងការបង្កើតឡើងវិញនូវរមណីយដ្ឋានតាមជនបទ ទីក្រុង រមណីយដ្ឋានប្រវត្តិសាស្ត្រ និងលើកតម្កើងការអភិរក្សអភិវឌ្ឍន៍សម្បត្តិវប្បធម៌ធម្មជាតិ។

ទេសចរអន្តរជាតិជាច្រើននៅលើពិភពលោកកំពុងសម្លឹងមើលវិស័យទេសចរណ៍ក្នុងទំរង់ជនបទ ដែលការអភិវឌ្ឍផ្ទះស្នាក់មានលក្ខណៈជាប្រព័ន្ធដោយមានពាក់ព័ន្ធនឹងសហគមន៍ រដ្ឋាភិបាល ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល។ កម្មវិធីផ្ទះស្នាក់មានលក្ខណៈសំខាន់ក្នុងការបង្កើតនូវបទពិសោធន៍ថ្មីដល់ទេសចរ ដោយបង្ហាញពីគុណភាពរស់នៅតាមជនបទតាមរយៈការផ្តល់នូវគុណតម្លៃសម្រាប់ការឈប់សំរាកលំហែកម្សាន្តប្រកបដោយ

ការអប់រំ និងមានកម្រិតវប្បធម៌ប្រពៃណីតាមតំបន់។ ចំណុចលក់នៃកម្មវិធីផ្ទះស្នាក់មិនត្រឹមតែសំដៅលើការផ្តល់សេវាកម្មស្នាក់នៅ និងសេវាកម្មចំណីអាហារប៉ុណ្ណោះទេ ប៉ុន្តែគឺសំដៅឆ្ពោះទៅការលក់កញ្ចប់ទស្សនកិច្ចតាមភូមិបន្ថែមទៀត ដែលសកម្មភាពទាំងនេះជាកត្តាមានឥទ្ធិពលខ្លាំងក្នុងការផ្តល់នូវបទពិសោធន៍ដែលមិនអាចបំភ្លេចបានដល់ភ្ញៀវទេសចរ។

ជោគជ័យនៃកម្មវិធីផ្ទះស្នាក់ទាមទារឲ្យមានការពឹងផ្អែកខ្ពស់លើការយល់ដឹងពីតម្រូវការមូលដ្ឋាន និងចំណង់ចំណូលចិត្តរបស់ភ្ញៀវ ការរៀបចំ និងអភិវឌ្ឍន៍សម្បទាគាំទ្រផ្សេងៗដែលរួមចំណែកក្នុងការលើកកំពស់គុណភាពសេវាកម្មទេសចរណ៍ផ្តល់នូវបទពិសោធន៍ដល់ភ្ញៀវប្រកបដោយគុណភាព និងមានភាពទាក់ទាញ។ ដូច្នេះការបង្កើតស្តង់ដាផ្ទះស្នាក់ជាការចាំបាច់ដើម្បីផ្តល់ឱកាសឲ្យប្រជាជនសហគមន៍ និងម្ចាស់ផ្ទះស្នាក់ទាំងអស់អាចអភិវឌ្ឍសេវាកម្មផ្ទះស្នាក់របស់ខ្លួនប្រកបដោយគុណភាពទទួលបានការទទួលស្គាល់នូវកំរិតគុណភាពមួយជាក់លាក់ និងទាក់ទាញភ្ញៀវទេសចរមកកំសាន្តកាន់តែច្រើន នាំមកនូវប្រាក់ចំណូលដល់ប្រជាជនសហគមន៍នៅទីនឹងកន្លែង។

## II-និយមន័យ

ស្តង់ដាផ្ទះស្នាក់កម្ពុជាផ្តោតទៅលើផ្ទះស្នាក់សហគមន៍ ផ្ទះស្នាក់ជនបទ និងផ្ទះស្នាក់ទីក្រុង។

- **ផ្ទះស្នាក់សហគមន៍** គឺជាកន្លែងដែលភ្ញៀវស្នាក់នៅជាមួយគ្រួសារម្ចាស់ផ្ទះ និងទទួលបានបទពិសោធន៍ពីការរស់នៅប្រចាំថ្ងៃនៃគ្រួសារម្ចាស់ផ្ទះ និងសហគមន៍ដោយផ្ទាល់ ឬដោយប្រយោល។ ស្តង់ដាផ្ទះស្នាក់សហគមន៍ផ្តោតលើ **៩សូចនាករគោល** រួមមាន **២៨សូចនាករលំអិត** និង **៩៣លក្ខណៈវិនិច្ឆ័យ**។
- **ផ្ទះស្នាក់ជនបទ** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅស្ថានប្រជាពលរដ្ឋនៅតាមកសិដ្ឋាន ចំការ ឬវាលស្រែតាមតំបន់ជនបទដែលម្ចាស់កសិដ្ឋាន ម្ចាស់ចំការ ឬប្រជាកសិករធ្វើការរៀបចំឲ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ *(ពិសេសអាហារពេលព្រឹក)* សម្រាប់ទទួលភ្ញៀវទេសចរមកធ្វើវិស្សមកាល ឬដំណើរកំសាន្តដែលមកទស្សនាកំសាន្តតំបន់នោះចាប់ពី ០១យប់ ឬអ្នកបំរើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ននៅតាមសហគមន៍ ឬជនបទ។ ផ្ទះស្នាក់ជនបទជាសម្បទាស្នាក់នៅសាមញ្ញមួយបែបដែលបំរើដល់ **វិស័យកសិ-ទេសចរណ៍** ដែលកសិករ ឬម្ចាស់កសិដ្ឋានជាអ្នកដើរតួជាម្ចាស់សេវាកម្មរៀបចំសម្រាប់ទទួលភ្ញៀវទេសចរតែម្តង។ ស្តង់ដាផ្ទះស្នាក់ជនបទផ្តោតលើ **៨សូចនាករគោល ១៥សូចនាករលំអិត** និង **៩៤លក្ខណៈវិនិច្ឆ័យ**។
- **ផ្ទះស្នាក់ទីក្រុង** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅស្ថានប្រជាពលរដ្ឋនៅទីក្រុង ឬតាមទីប្រជុំជន ដែលម្ចាស់ផ្ទះធ្វើការរៀបចំឲ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ *(ពិសេសអាហារពេលព្រឹក)* សម្រាប់ទទួលភ្ញៀវទេសចរមកធ្វើវិស្សមកាល ឬដំណើរទស្សនាកំសាន្តតំបន់នោះចាប់ពី ០១យប់ ឬអ្នកបំរើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ននៅទីក្រុង ឬទីប្រជុំជន។ ផ្ទះស្នាក់ទីក្រុង គឺជាផ្ទះស្នាក់នៅតាមទីក្រុង ឬទីប្រជុំជនដែលប្រជាជនអាចរៀបចំឡើងដើម្បីទទួលភ្ញៀវដោយផ្អែកលើទិដ្ឋភាព **០៣យ៉ាង** គឺ**ភាពស្អាត** *(Cleanliness)* **របៀបរៀបរយ** *(Order Arrangement)* និង**បដិសណ្ឋារកិច្ច** (Hospitality)។ ស្តង់ដាផ្ទះស្នាក់ទីក្រុងផ្តោតលើ **៧សូចនាករគោល ១៤សូចនាករលំអិត** និង **៤៧លក្ខណៈវិនិច្ឆ័យ**។

## III- ស្តង់ដាផ្ទះស្នាក់សហគមន៍

ស្តង់ដាផ្ទះស្នាក់សហគមន៍ផ្តោតលើ **៩សូចនាករគោល** រួមមាន **២៨សូចនាករលំអិត** និង **៩៣លក្ខណៈវិនិច្ឆ័យ**។

**សូចនាករគោល៩** រួមមាន៖

**១-ម្ចាស់ផ្ទះស្នាក់ ២-កន្លែងស្នាក់នៅ ៣-ទីតាំង ៤-អនាម័យ និងភាពស្អាត ៥- សកម្មភាពកំសាន្ត ៦-សន្តិសុខសុវត្ថិភាព ៧-ការគ្រប់គ្រង ៨-ការសិក្សាទីផ្សារ និងផ្សព្វផ្សាយ ៩-គោលការណ៍និរន្តរភាព។**

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យចាំបាច់ |
|---|---|---|---|
| ១- ម្ចាស់ផ្ទះស្នាក់ | ២ | ៦ | ៤ |
| ២- កន្លែងស្នាក់នៅ | ៤ | ១៣ | ៦ |
| ៣- ទីតាំង | ១ | ២ | ១ |
| ៤- អនាម័យ និងភាពស្អាត | ៣ | ១៦ | ៥ |
| ៥- សកម្មភាពកំសាន្ត | ៣ | ៦ | ២ |
| ៦- សន្តិសុខសុវត្ថិភាព | ៤ | ១៣ | ៤ |
| ៧-ការគ្រប់គ្រង | ៥ | ១០ | ២ |
| ៨- ការសិក្សាទីផ្សារ និងផ្សព្វផ្សាយ | ៣ | ៨ | ២ |
| ៩- គោលការណ៍និរន្តរភាព | ៣ | ១៩ | ៥ |
| **សរុប** | **២៨** | **៩៣** | **(៣១)** |

### តារាងសូចនាករគោលនៃការវាយតម្លៃផ្ទះស្នាក់សហគមន៍ ÷

#### ១- សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់

| សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-អ្នកភូមិ និងសហគមន៍ | • មានទីតាំងនៅជិតតំបន់ធម្មជាតិ និងវប្បធម៌<br>➢ មានចំងាយប្រមាណជា៖ ៥-១០គម | មាន-មិនមាន (*)[1] | ១ |
| | • ធ្លាប់ទទួលបានបណ្ណសសើរពីការប្រកួតប្រជែងក្នុងភូមិ | មាន-មិនមាន | ១ |
| | • មានមជ្ឈមណ្ឌលសហគមន៍នៅក្នុងភូមិ | មាន-មិនមាន (*) | ១ |
| | • មានបទបញ្ជាផ្ទៃក្នុង និងក្រុមសីលធម៌ | មាន-មិនមាន | ១ |
| ២-អ្នកផ្តល់សេវាផ្ទះស្នាក់ | • អ្នកផ្តល់សេវាផ្ទះស្នាក់បានទទួលការបណ្តុះបណ្តាលស្តីអំពីសេវាកម្មផ្ទះស្នាក់ | មាន-មិនមាន (*) | ១ |
| | • អ្នកផ្តល់សេវាផ្ទះស្នាក់ត្រូវពិនិត្យសុខភាពជារៀងរាល់ | មាន-មិនមាន (*) | ១ |

[1] (*)លក្ខណៈវិនិច្ឆ័យចាំបាច់

| | | | |
|---|---|---|---|
| | ៦ខែម្តង | | |
| | -ចំនួនសូចនាករលំអិត ៖ ២<br>-ចំនួនលក្ខណៈវិនិច្ឆ័យ ៖ ៦<br>-ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៤ | **សរុប** | **៦** |

## ២- សូចនាករគោលនៃកន្លែងស្នាក់នៅ

| សូចនាករគោលនៃកន្លែងស្នាក់នៅ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ផ្ទះ | • សំណង់ផ្ទះត្រូវរឹងមាំ និងមានលក្ខណៈសមរម្យ | មាន-មិនមាន (*) | ១ |
| | • សំណង់ផ្ទះឆ្លុះបញ្ចាំងពីរចនាបទ និងស្ថាបត្យកម្មខ្មែរតាមអត្តសញ្ញាណស្រុកភូមិ | មាន-មិនមាន | ១ |
| | • មានបន្ទប់ដាច់ដោយឡែកសម្រាប់ភ្ញៀវ<br>➢ ចំនួនបន្ទប់ភ្ញៀវ៖........... | មាន-មិនមាន | ១ |
| | • មានបន្ទប់ទឹក ឬបង្គន់អនាម័យសម្រាប់ភ្ញៀវយ៉ាងតិច០១៖<br>➢ ចំនួនបន្ទប់ទឹក ឬបង្គន់អនាម័យ៖ ........... | មាន-មិនមាន (*) | ១ |
| | • មានការផ្គត់ផ្គង់ថាមពលអគ្គិសនី (ការប្រើអាគុយ ថាមពលកកើតឡើងវិញជាដើម)............ | មាន-មិនមាន (*) | ១ |
| | • មានការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងផ្ទះគ្រប់គ្រាន់ និងគ្រប់ពេលវេលា (ទឹកអណ្តូងជាដើម) | មាន-មិនមាន (*) | ១ |
| ២-បន្ទប់គេង | • មានការផ្គត់ផ្គង់ដូចជា កង្ហារ តុ កៅអី កញ្ចក់ មុងខ្សែភ្លើង<br>➢ សម្ភារបន្ទប់គេងមាន៖ ......... | មាន-មិនមាន (*) | ១ |
| | • មានបន្ទប់ភ្ញៀវយ៉ាងច្រើនចំនួន ៤បន្ទប់ដោយក្នុងមួយបន្ទប់មិនអាចលើសពី ២នាក់ | មាន-មិនមាន | ១ |
| | • មានស្រោមខ្នើយ និងកំរាលពូកស្អាតសម្រាប់ភ្ញៀវ | មាន-មិនមាន | ១ |
| ៣- បង្គន់អនាម័យ និងបន្ទប់ទឹក | • បន្ទប់ទឹក និងបង្គន់អនាម័យនៅក្នុងផ្ទះ ឬក្រៅផ្ទះត្រូវមានសោ ឬគន្លឹះ | មាន-មិនមាន | ១ |
| | • បន្ទប់ទឹក និងបង្គន់អនាម័យមានសម្ភារសម្រាប់ប្រើដូចជា៖ ធុងសំរាម ប្រដាប់ផ្តក់កន្សែងជាប់ជញ្ជាំង ប្រដាប់ដាក់សាប៊ូ កញ្ចក់ឆ្លុះមុខ | មាន-មិនមាន | ១ |
| ៤- ផ្ទះបាយ | • ផ្ទះត្រូវមានបន្ទប់ ឬកន្លែងរៀបចំចំអិនអាហារដាច់ដោយឡែក និងមានលក្ខណៈសមរម្យ | មាន-មិនមាន (*) | ១ |
| | • ត្រូវមានទូ ឬកន្លែងទុកដាក់សម្ភារៈចំអិនម្ហូបត្រឹមត្រូវ | មាន-មិនមាន | ១ |
| | - **ចំនួនសូចនាករលំអិត៖ ៤** | **សរុប** | **១៣** |

| | | | |
|---|---|---|---|
| - ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១៣<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៦ | | | |

## ៣- សូចនាករគោលនៃទីតាំង

| សូចនាករគោលនៃទីតាំង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១- នៅតំបន់ដែលអាចធ្វើដំណើរទៅដល់ | • ទីតាំងផ្ទះស្នាក់គួរទៅដល់បានតាមមធ្យោបាយណាមួយក៏បាន | មាន-មិនមាន (*) | ១ |
| | • មានផ្លាកសញ្ញាត្រឹមត្រូវ និងច្បាស់លាស់បង្ហាញផ្លូវទៅកាន់ផ្ទះស្នាក់ | មាន-មិនមាន | ១ |
| - ចំនួនសូចនាករលំអិត៖១<br>- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ២<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ១ | | សរុប | ២ |

## ៤- សូចនាករគោលនៃអនាម័យ និងភាពស្អាត

| សូចនាករគោលនៃអនាម័យ និងភាពស្អាត | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ផ្ទះ (ផ្ទះបាយ បន្ទប់គេង បង្គន់ បន្ទប់ទឹក) | • រាល់បន្ទប់គេង ផ្ទះបាយ និងបង្គន់ត្រូវសំអាតឲ្យបានស្អាតជានិច្ច ជៀសផុតពីធូលី និងក្លិនស្អុយ | មាន-មិនមាន (*) | ១ |
| | • កំរាលឥដ្ឋ ឬឈើនៃផ្ទះបាយត្រូវសំអាតឲ្យបានស្អាត | មាន-មិនមាន | ១ |
| | • បន្ទប់ទឹក បង្គន់ ផ្កាឈូកងូតទឹក ត្រូវសំអាតគ្មានស្នាមប្រលាក់ ឬដុះស្លែ | មាន-មិនមាន | ១ |
| | • ប្រើថ្នាំសំលាប់មេរោគក្នុងបង្គន់ | មាន-មិនមាន | ១ |
| | • ផ្តល់នូវសាប៊ូដុសខ្លួន សាប៊ូកក់សក់ ក្រដាសអនាម័យ និងកន្សែងស្អាត | មាន-មិនមាន | ១ |
| ២-បរិវេណជុំវិញផ្ទះ | • គ្មានសម្រាមនៅបរិវេណជុំវិញផ្ទះ(ពិសេសថង់ផ្លាស្ទិច) និងត្រូវមានធុងសំរាមតាមផ្ទះនីមួយៗ | មាន-មិនមាន (*) | ១ |
| | • គ្មានវត្ថុដែលអាចបង្កជាជម្រកមូស | មាន-មិនមាន | ១ |
| | • រក្សាសោភណ្ឌភាពភូមិដោយដាំដើមឈើ | មាន-មិនមាន | ១ |
| ៣-ការរៀបចំអាហារ | • ផ្ទះបាយត្រូវស្អាត និងមានខ្យល់ចេញចូល | មាន-មិនមាន (*) | ១ |
| | • ប្រដាប់ប្រដាប្រើនៅផ្ទះបាយត្រូវមានលក្ខណៈល្អស្អាត និងរក្សានៅទីកន្លែងត្រឹមត្រូវ និងស្ងួត | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | • មិនប្រើប្រាស់ចាន កែវ ដែលប្រេះ ឬស្រាំ | មាន-មិនមាន | ១ |
| | • បុគ្គលដែលចូលរួមចំអិនអាហារត្រូវមានអនាម័យ និងមានសំលៀកបំពាក់ត្រឹមត្រូវ | មាន-មិនមាន | ១ |
| | • ប្រើប្រាស់ សាច់ បន្លែ និងគ្រឿងចំអិនអាហារដែលទិញនៅក្នុងភូមិ | មាន-មិនមាន (*) | ១ |
| | • អាហារសម្រាប់ភ្ញៀវត្រូវគ្របទុកឲ្យបានត្រឹមត្រូវ និងប្រកបដោយអនាមយ័ល្អ | មាន-មិនមាន | ១ |
| | • ផ្តល់ទឹកស្អាតដែលមានសុវត្ថិភាពក្នុងការទទួលទានដល់ភ្ញៀវ | មាន-មិនមាន (*) | ១ |
| | • មានការផ្តល់ព័ត៌មាន និងប្រវត្តិមុខម្ហូបប្រចាំថ្ងៃ | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត៖ ៣<br>- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១៦<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៥** | | **សរុប** | **១៦** |

## ៥- សូចនាករគោលនៃសកម្មភាពកំសាន្ត

| **សូចនាករគោលនៃសកម្មភាពកំសាន្ត** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១-សកកម្មភាពតាមភូមិ និងសហគមន៍ | • បង្ហាញពីធនធានក្នុងភូមិដូចជា កេរ្តិ៍ដំណែលវប្បធម៌ បេតិកភណ្ឌ សហគ្រាសខ្នាតតូច ឬធនធានធម្មជាតិ | មាន-មិនមាន (*) | ១ |
| | • ជំរុញឲ្យមានសកម្មភាពកំសាន្តនានា ដោយមានការចូលរួមរវាងភ្ញៀវទេសចរ និងអ្នកភូមិ | មាន-មិនមាន | ១ |
| ២- សកម្មភាពជុំវិញភូមិជិតខាង | • បញ្ចូលខ្សែទស្សនកិច្ចតាមតំបន់ទាក់ទាញទេសចរណ៍ជុំវិញភូមិជិតខាង | មាន-មិនមាន | ១ |
| | • សហការជាមួយភូមិជិតខាងដើម្បីបន្ថែមសកម្មភាពកំសាន្ត | មាន-មិនមាន | ១ |
| ៣-អត្តសញ្ញាណដើម | • សហគមន៍រក្សាអត្តសញ្ញាណ តម្លៃ និងវប្បធម៌របស់ខ្លួន (ដូចជា: ភាសា ការស្លៀកពាក់ អាហារ និងជីវភាពរស់នៅប្រចាំថ្ងៃជាដើម) | មាន-មិនមាន (*) | ១ |
| | • ថែរក្សាសិប្បកម្មប្រពៃណីក្នុងភូមិ និងបង្ហាញទំនៀមទំលាប់តាមរយៈការសម្តែងសិល្ប:របស់អ្នកភូមិ | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត៖ ៣** | | **សរុប** | **៦** |

| | | | |
|---|---|---|---|
| - ចំនួនលក្ខណៈវិនិច្ឆ័យ៖ ៦<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ២ | | | |

## ៦-សូចនាករគោលនៃសន្តិសុខសុវត្ថិភាព

| សូចនាករគោលនៃសន្តិសុខសុវត្ថិភាព | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ការបណ្តុះបណ្តាលពីសន្តិសុខសុវត្ថិភាព | • បុគ្គលិកអមភ្ញៀវបានទទួលការបណ្តុះបណ្តាលអំពីការសង្គ្រោះបន្ទាន់បឋម | មាន-មិនមាន (*) | ១ |
| | • មានប្រជាការពាររក្សាសណ្តាប់ធ្នាប់ | មាន-មិនមាន | ១ |
| ២- សន្តិសុខសុវត្ថិភាព | • មានប្រអប់ថ្នាំសម្រាប់ព្យាបាលការឈឺថ្កាត់បឋម និងមានលេខទូរស័ព្ទឡានសង្គ្រោះបន្ទាន់ ឬមន្ទីរពេទ្យដែលនៅជិត | មាន-មិនមាន | ១ |
| | • យ៉ាងហោចណាស់មានអ្នកអមភ្ញៀវចំនួន ២រូប ក្នុងសកម្មភាពកំសាន្ត | មាន-មិនមាន | ១ |
| | • សកម្មភាពកំសាន្តពាក់ព័ន្ធនឹងទឹកត្រូវមានអាវការពារ ឬឧបករណ៍ការពារផ្សេងៗ | មាន-មិនមាន (*) | ១ |
| | • កំពង់ទូកជសម្រាប់ចតទូកត្រូវមានរបាំងការពារត្រឹមត្រូវ និងក្តារក្រាលមិនរអិល | មាន-មិនមាន | ១ |
| | • ផ្លូវលំតូចៗ និងផ្លូវក្នុងភូមិត្រូវមានផ្លាកសញ្ញា | មាន-មិនមាន | ១ |
| ៣- ការណែនាំអំពីសុវត្ថិភាព | • ពន្យល់ណែនាំអំពីកត្តាសុវត្ថិភាពមុនភ្ញៀវចូលរួមកម្មវិធីកំសាន្តនានា | មាន-មិនមាន (*) | ១ |
| | • មានឯកសារណែនាំពីការរក្សាសុវត្ថិភាពភ្ញៀវ | មាន-មិនមាន | ១ |
| | • គួរចុះឈ្មោះនិងទុកលេខទំនាក់ទំនងរបស់ភ្ញៀវដែលចូលរួមដំណើរកំសាន្តបែបអេកូទេសចរណ៍ផ្សងព្រេង | មាន-មិនមាន | ១ |
| ៤-ការសង្គ្រោះបឋម និងការជន្លៀសពេលមានអាសន្ន | • បុគ្គលិកអមភ្ញៀវត្រូវបំពាក់ឧបករណ៍សម្រាប់សង្គ្រោះបឋម | មាន-មិនមាន (*) | ១ |
| | • បុគ្គលិកអមភ្ញៀវត្រូវបំពាក់ឧបករណ៍សម្រាប់ទំនាក់ទំនង | មាន-មិនមាន | ១ |
| | • អនុវត្តតាមគោលការណ៍សុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា | មាន-មិនមាន | ១ |
| - ចំនួនសូចនាករលំអិត៖ ៤ | | សរុប | ១៣ |

| | | |
|---|---|---|
| - ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១៣<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៤ | | |

## ៧- សូចនាករគោលនៃការគ្រប់គ្រង

| សូចនាករគោលនៃការគ្រប់គ្រង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ការដឹកនាំ | • ប្រធានសហគមន៍ត្រូវមានក្រមសីលធម៌ ប្តេជ្ញាចិត្តខ្ពស់ ស្មារតីទទួលខុសត្រូវ និងទទួលបានការគោរពពីអ្នកភូមិ | មាន-មិនមាន | ១ |
| ២-ការរៀបចំចាត់ចែង | • សហគមន៍ផ្ទះស្នាក់មានរចនាសម្ព័ន្ធ ការទទួលខុសត្រូវច្បាស់លាស់ និងមានទំនាក់ទំនងតាមផ្នែកនីមួយៗ | មាន-មិនមាន (*) | ១ |
| | • មានការលើកទឹកចិត្តផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងយុវជនពីសហគមន៍ | មាន-មិនមាន | ១ |
| | • សហគមន៍ផ្ទះស្នាក់ ទទួលបានការគាំទ្រពីអាជ្ញាធរ ភូមិ ឃុំ | មាន-មិនមាន | ១ |
| ៣- ទិន្នន័យ | • សហគមន៍មានប្រព័ន្ធទិន្នន័យផ្ទះស្នាក់៖ ទិន្នន័យភ្ញៀវ អាស័យដ្ឋានផ្ទះស្នាក់ ចំនួនសមាជិកគ្រួសារ ជំនាញពិសេស និងចំណេះដឹងផ្សេងៗ | មាន-មិនមាន (*) | ១ |
| | • ម្ចាស់ផ្ទះស្នាក់មានទិន្នន័យភ្ញៀវ ៖ កត់ត្រាកាលបរិច្ឆេទ ការមកដល់ការត្រឡប់ទៅវិញរបស់ភ្ញៀវ ឈ្មោះប្រទេស និងយោបល់របស់ភ្ញៀវ | មាន-មិនមាន | ១ |
| | • មានទិន្នន័យរមណីយដ្ឋានទេសចរណ៍ក្នុងភូមិ និងរមណីយដ្ឋានទេសចរណ៍បង្កើតថ្មី និងព័ត៌មានស្តីពីតំបន់ទេសចរណ៍ថ្មីៗនៅក្នុងភូមិ និងតំបន់ជុំវិញ | មាន-មិនមាន | ១ |
| ៤-ការបណ្តុះបណ្តាលសមត្ថភាព | • សហគមន៍មានឯកសារណែនាំស្តីពីៈ<br>➢ ការស្វាគមន៍ និងការទទួលភ្ញៀវ<br>➢ ការចុះឈ្មោះការចេញវិក័យប័ត្រ និងការបង់ប្រាក់<br>➢ ភាពស្អាត និងអនាម័យ<br>➢ ចំណេះដឹងខ្លះៗក្នុងការប្រាស្រ័យទាក់ទងគ្នា<br>➢ រៀបផែនការចាត់ចែង សកម្មភាពកំសាន្តនានា<br>➢ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយ<br>➢ ចំណេះដឹងក្នុងការនិយាយបកស្រាយពីប្រវត្តិផ្សេងៗ | មាន-មិនមាន | ១ |
| | • សហគមន៍មានកម្មវិធីបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍រវាងសហគមន៍ និងសហគមន៍ | មាន-មិនមាន | ១ |
| ៥- កិច្ចសហការ | • មានទំនាក់ទំនងល្អជាមួយដៃគូរៈសហគមន៍ផ្ទះស្នាក់ | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | ទីភ្នាក់ងារឯកជន គ្រឹះស្ថានអប់រំសាធារណៈ និងអង្គការនានា | | |
| | **- ចំនួនសូចនាករលំអិត៖ ៥**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១០**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ២** | **សរុប** | **១០** |

## ៨- សូចនាករគោលនៃការសិក្សាទីផ្សារ និងផ្សព្វផ្សាយ

| **សូចនាករគោលនៃការសិក្សាទីផ្សារ និងផ្សព្វផ្សាយ** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១-សកម្មភាព ផ្សព្វផ្សាយ | • រៀបចំកញ្ចប់កម្មវិធីឲ្យសមស្របនឹងតម្រូវការរបស់ភ្ញៀវ | មាន-មិនមាន (*) | ១ |
| | • កំណត់លក្ខណៈពិសេស និងភាពទាក់ទាញរបស់ភូមិ | មាន-មិនមាន (*) | ១ |
| | • បោះពុម្ពឯកសារផ្សព្វផ្សាយ ដូចជាប័ណ្ណផ្ទត់ | មាន-មិនមាន | ១ |
| | • សហការជាមួយស្ថាប័នថ្នាក់ក្រោមជាតិ និងផ្នែកឯកជន ដើម្បីធ្វើការងារសិក្សាទីផ្សារ | មាន-មិនមាន | ១ |
| ២-សហការជាដៃគូជាមួយផ្នែកឯកជន | • រៀបចំដំណើរទស្សនកិច្ចដោយអញ្ជើញផ្នែកឯកជនមកទស្សនា និងសិក្សាស្វែងយល់ពីសេវាផ្ទះស្នាក់ | មាន-មិនមាន | ១ |
| | • មានកិច្ចសហការជាដៃគូជាមួយប្រតិបត្តិករទេសចរណ៍ ឬជម្រុញឲ្យពួកគេក្លាយជាអ្នកប្រឹក្សាយោបល់ទេសចរណ៍ | មាន-មិនមាន | ១ |
| ៣-ការផ្សព្វផ្សាយតាមអ៊ីនធឺណែត | • មានគេហទំព័រ និងមានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយផ្ទះស្នាក់ និងសម្រួលដល់ការកក់តាមប្រព័ន្ធអ៊ីនធឺណែត | មាន-មិនមាន | ១ |
| | • យុវជនក្នុងភូមិចូលរួមក្នុងការពិនិត្យតាមដាន និងសម្រួលខ្លឹមសារផ្សព្វផ្សាយក្នុងគេហទំព័រ | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិត៖ ៣**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ៨**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ២** | **សរុប** | **៨** |

## ៩-សូចនាករគោលនៃគោលការណ៍និរន្តរភាព

| **សូចនាករគោលនៃគោលការណ៍និរន្តរភាព** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១-និរន្តរភាព | • ការផ្តល់ការងារ | | |

| | | | |
|---|---|---|---|
| សេដ្ឋកិច្ច | ➢ សហគមន៍ផ្ទះស្នាក់ជ្រើសរើសបុគ្គលិកពីក្នុងភូមិរបស់ខ្លួន | មាន-មិនមាន (*) | ១ |
| | ➢ មានគោលការណ៍លើកទឹកចិត្តបុគ្គលិក | មាន-មិនមាន | ១ |
| | ➢ ប្រើប្រាស់មគ្គុទ្ទេសក៏ទេសចរណ៍របស់សហគមន៍ | មាន-មិនមាន | ១ |
| | ➢ សហគមន៍គួរផ្តល់ប្រាក់កម្ចីទ្រង់ទ្រាយតូច (បានមកពីមូលនិធិសហគមន៍)ដល់ប្រជាជនសហគមន៍ដែលមានបំណងបង្កើតផ្ទះស្នាក់ | មាន-មិនមាន | ១ |
| | • ការទិញទំនិញ | | |
| | ➢ សហគមន៍ផ្ទះស្នាក់ត្រូវព្យាយាមទិញទំនិញ និងផលិតផលដែលផលិតក្នុងភូមិ | មាន-មិនមាន (*) | ១ |
| | ➢ គួរជំរុញភ្ញៀវឲ្យចូលរួមទិញផលិតផលក្នុងភូមិ | មាន-មិនមាន | ១ |
| | ➢ មានកន្លែងដាក់បង្ហាញ និងលក់វត្ថុអនុស្សាវរីយ៏នៅមជ្ឍមណ្ឌលផ្ទះស្នាក់ | មាន-មិនមាន | ១ |
| | • ការផ្សព្វផ្សាយផលិតផលទេសចរណ៍ក្នុងភូមិ និងតំបន់ទាក់ទាញនិញ | | |
| | ➢ ផ្សព្វផ្សាយព្រឹត្តិការណ៍ក្នុងភូមិ | មាន-មិនមាន | ១ |
| | ➢ ផ្តល់ជូនភ្ញៀវនូវទំនិញ និងសេវាកម្ម ដូចជាៈ វត្ថុអនុស្សាវរីយ៏បែបប្រពៃណីក្នុងមូលដ្ឋាន និងម្ហូបអាហារប្រចាំភូមិ | មាន-មិនមាន | ១ |
| ២-និរន្តរភាពបរិស្ថាន | • មានការដាក់កំរិតនានាដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ធម្មជាតិ និងវប្បធម៌ដែលអាចបង្កឡើងដោយភ្ញៀវទេសចរ | មាន-មិនមាន (*) | ១ |
| | • ហាមឃាត់ភ្ញៀវទេសចរក្នុងការចូលរួមសកម្មភាពណាដែលអាចប៉ះពាល់ដល់ធម្មជាតិ | មាន-មិនមាន (*) | ១ |
| | • ភ្ញៀវទេសចរចូលរួមក្នុងកម្មវិធីដាំដើមឈើក្នុងភូមិ កម្មវិធីសំអាតភូមិ និងសកម្មភាពនានាចូលរួមចំណែកអនុវត្តច្បាប់កិច្ចការពារបរិស្ថាន | មាន-មិនមាន | ១ |
| | • រៀបចំក្រមសីលធម៌ ឬគួរធ្វើ និងមិនគួរធ្វើ (Dos and Don'ts) ដើម្បីចែកជូនដល់ភ្ញៀវ | មាន-មិនមាន | ១ |
| | • សហគមន៍ទទួលបានការអប់រំ និងណែនាំពីសារៈសំខាន់នៃការថែរក្សាជីវចំរុះជុំវិញ | មាន-មិនមាន | ១ |
| | • ការរៀបចំផ្ទះ និងសំណង់ផ្សេងៗគួរមានការគិតគូរដល់បរិស្ថានបៃតង | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| ៣-និរន្តរភាពនៃសង្គមវប្បធម៌ | • សហគមន៍គួរមានកន្លែងផ្ដល់ព័ត៌មាន និងតាំងបង្ហាញវត្ថុវប្បធម៌នានានៅមជ្ឈមណ្ឌលសហគមន៍ | មាន-មិនមាន | ១ |
| | • ជម្រាបជូនភ្ញៀវអំពីការគោរពដល់ទំនៀមទំលាប់ប្រពៃណីក្នុងសហគមន៍ និងអាកប្បកិរិយាសមរម្យ | មាន-មិនមាន | ១ |
| | • ប្រជាជនសហគមន៍ទទួលបានការណែនាំអំពីសារៈសំខាន់នៃការថែរក្សាប្រពៃណី និងវប្បធម៌របស់ខ្លួន | មាន-មិនមាន | ១ |
| | • ទប់ស្កាត់រាល់អំពើទាំងឡាយណាពាក់ព័ន្ធនឹងការជួញដូរមនុស្ស គ្រឿងញៀន និងការប្រព្រឹត្តបទល្មើសទាំងឡាយណាដែលផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា | មាន-មិនមាន (*) | ១ |
| | **- ចំនួនសូចនាករលំអិត៖ ៣**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១៩**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៥** | **សរុប** | **១៩** |

## IV- ស្តង់ដាផ្ទះស្នាក់ជនបទ

នៅប្រទេសកម្ពុជា **ផ្ទះស្នាក់ជនបទ** គឺជាទស្សនទានថ្មីមួយទៀតសម្រាប់ប្រជាកសិករ ឬម្ចាស់កសិដ្ឋាន ប៉ុន្តែវាអាចមានទម្រង់ប្រហាក់ប្រហែលនឹងផ្ទះស្នាក់សហគមន៍ (Homestay)ដែរ។ **ផ្ទះស្នាក់ជនបទ គឺជាផ្ទះស្នាក់នៅតាមជនបទស្រុកស្រែចំការ តាមវាលស្រែ ឬក្នុងកសិដ្ឋាន ដែលប្រជាជនអាចរៀបចំឡើងផ្អែកលើទិដ្ឋភាព ០៣យ៉ាង គឺភាពស្អាត** (Cleanliness) **របៀបរៀបរយ** (Order Arrangement) **និង បដិសណ្ឋារកិច្ច** (Hospitality)។

ស្តង់ដាផ្ទះស្នាក់ជនបទផ្តោតលើ **៨សូចនាករគោល ១៥សូចនាករលំអិត** និង **៤៤លក្ខណៈវិនិច្ឆ័យ**។

សូចនាករគោល៨រួមមាន ៖ **១- ម្ចាស់ផ្ទះស្នាក់ ២-កន្លែងស្នាក់នៅ ៣-ទីតាំង ៤-អនាម័យ និងភាពស្អាត ៥-សកម្មភាពកំសាន្ត ៦- សន្តិសុខសុវត្ថិភាព ៧- ការផ្សព្វផ្សាយ ៨- គោលការណ៍និរន្តរភាព**

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យចាំបាច់ |
|---|---|---|---|
| ១-ម្ចាស់ផ្ទះស្នាក់ | ១ | ២ | ២ |
| ២- កន្លែងស្នាក់នៅ | ៤ | ១៣ | ៦ |
| ៣- ទីតាំង | ១ | ២ | ១ |
| ៤- អនាម័យ និងភាពស្អាត | ៣ | ១៦ | ៥ |
| ៥- សកម្មភាពកំសាន្ត | ១ | ២ | ០ |
| ៦- សន្តិសុខសុវត្ថិភាព | ១ | ២ | ០ |
| ៧- ការផ្សព្វផ្សាយ | ១ | ១ | ០ |
| ៨- គោលការណ៍និរន្តរភាព | ៣ | ៦ | ៣ |
| **សរុប** | **១៥** | **៤៤** | **១៧** |

## តារាងសូចនាករគោលនៃការវាយតម្លៃផ្ទះស្នាក់ជនបទ ៖

### ១- សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់

| សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ម្ចាស់ផ្ទះស្នាក់ | • អ្នកផ្តល់សេវាផ្ទះស្នាក់ជនបទបានទទួលការបណ្តុះបណ្តាលស្តីពីសេវាកម្មបដិសណ្ឋារកិច្ចនិងភាសាអង់គ្លេសចាំបាច់ជាមូលដ្ឋាននានា | មាន-មិនមាន (*)[2] | ១ |
| | • អ្នកផ្តល់សេវាផ្ទះស្នាក់ជនបទត្រូវពិនិត្យសុខភាពជារៀងរាល់ ៦ខែម្តង | មាន-មិនមាន (*) | ១ |
| -ចំនួនសូចនាករលំអិត ៖ ១<br>-ចំនួនលក្ខណៈវិនិច្ឆ័យ ៖ ២<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ២ | | សរុប | ២ |

### ២- សូចនាករគោលនៃកន្លែងស្នាក់នៅ

| សូចនាករគោលនៃកន្លែងស្នាក់នៅ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ផ្ទះ | • សំណង់ផ្ទះត្រូវរឹងមាំ និងមានលក្ខណៈសមរម្យ | មានមិនមាន (*) | ១ |
| | • សំណង់ផ្ទះឆ្លុះបញ្ចាំងពីរចនាបទ និងស្ថាបត្យកម្មខ្មែរតាមអត្តសញ្ញាណស្រុក ភូមិ | មាន-មិនមាន | ១ |
| | • មានបន្ទប់ដាច់ដោយឡែកសម្រាប់ភ្ញៀវ<br>➢ ចំនួនបន្ទប់ភ្ញៀវ៖........... | មាន-មិនមាន | ១ |
| | • មានបន្ទប់ទឹក ឬបង្គន់អនាម័យសម្រាប់ភ្ញៀវយ៉ាងតិច ០១<br>➢ ចំនួនបន្ទប់ទឹក ឬបង្គន់អនាម័យ៖ ........... | មាន-មិនមាន (*) | ១ |
| | • មានការផ្គត់ផ្គង់ថាមពលអគ្គិសនី(ការប្រើប្រាស់អាគុយ ឬថាមពលកកើតឡើងវិញជាដើម) | មាន-មិនមាន (*) | ១ |
| | • មានការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងផ្ទះគ្រប់គ្រាន់ និងគ្រប់ពេលវេលា (ទឹកអណ្តូងជាដើម) | មាន-មិនមាន (*) | ១ |
| ២-បន្ទប់គេង | • មានការផ្គត់ផ្គង់ដូចជា កន្ទេល តុ កៅអី កញ្ចក់ មុង ខ្យល់ភ្លើង<br>➢ សម្បទាបន្ទប់គេងមាន៖ ......... | មាន-មិនមាន (*) | ១ |
| | • មានបន្ទប់ភ្ញៀវយ៉ាងច្រើនចំនួន ៤បន្ទប់ដោយក្នុងមួយបន្ទប់មិនលើសពី ២នាក់ | មាន-មិនមាន | ១ |
| | • មាន ស្រោមខ្នើយ និងកំរាលពូកស្អាតសម្រាប់ភ្ញៀវ | មាន-មិនមាន | ១ |
| ៣-បង្គន់អនាម័យ និងបន្ទប់ទឹក | • បន្ទប់ទឹក និងបង្គន់អនាម័យនៅក្នុងផ្ទះ ឬក្រៅផ្ទះ | មាន-មិនមាន | ១ |

[2] (*)លក្ខណៈវិនិច្ឆ័យចាំបាច់

| | | | |
|---|---|---|---|
| | ត្រូវមានសោ ឬគន្លឹះឲ្យបានត្រឹមត្រូវ | | |
| | • បន្ទប់ទឹក និងបង្គន់អនាម័យ មានសម្បទាសម្រាប់ប្រើ ដូចជា ៖ ធុងសំរាម ប្រដាប់ថ្លក់កន្សែងជាប់ជញ្ជាំង ប្រដាប់ដាក់សាប៊ូ កញ្ចក់ឆ្លុះមុខ | មាន-មិនមាន | ១ |
| ៤- ផ្ទះបាយ | • ផ្ទះត្រូវមានបន្ទប់ ឬកន្លែងរៀបចំចំអិនអាហារ ដាច់ដោយឡែក និងមានលក្ខណៈសមរម្យ | មាន-មិនមាន(*) | ១ |
| | • ត្រូវមានទូ ឬកន្លែងទុកដាក់សម្ភារៈចំអិនម្ហូបត្រឹមត្រូវ | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត៖ ៤<br>- ចំនួនលក្ខណវិនិច្ឆ័យ៖ ១៣<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៦** | | **សរុប** | **១៣** |

## ៣- សូចនាករគោលនៃទីតាំង

| សូចនាករគោលនៃទីតាំង | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១- តំបន់ដែលអាចធ្វើដំណើរទៅដល់ | • ទីតាំងផ្ទះស្នាក់គួរទៅដល់បានតាមមធ្យោបាយណាមួយក៏បាន | មាន-មិនមាន (*) | ១ |
| | • មានផ្លាកសញ្ញាត្រឹមត្រូវ និងច្បាស់លាស់ សម្រាប់បង្ហាញផ្លូវទៅកាន់ផ្ទះស្នាក់ជនបទ | មាន-មិនមាន | ១ |
| **- ចំនួនសូចនាករលំអិត៖១<br>- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ២<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ១** | | **សរុប** | **២** |

## ៤- សូចនាករគោលនៃអនាម័យ និងភាពស្អាត

| សូចនាករគោលនៃអនាម័យនិងភាពស្អាត | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ផ្ទះ (ផ្ទះបាយ បន្ទប់គេង បង្គន់ បន្ទប់ទឹក) | • រាល់បន្ទប់គេង ផ្ទះបាយ និងបង្គន់ត្រូវសំអាតឲ្យបានស្អាតជានិច្ច ជៀសផុតពីធូលី និងក្លិនស្អុយ | មាន-មិនមាន (*) | ១ |
| | • កំរាលឥដ្ឋ ឬឈើនៃផ្ទះបាយត្រូវសំអាតឲ្យបានស្អាត | មាន-មិនមាន | ១ |
| | • បន្ទប់ទឹក បង្គន់ ផ្កាឈូកងូតទឹក ត្រូវសំអាត គ្មានស្នាមប្រលាក់ ឬដុះស្លែ | មាន-មិនមាន | ១ |
| | • ប្រើថ្នាំសំលាប់មេរោគក្នុងបង្គន់ | មាន-មិនមាន | ១ |
| | • ផ្តល់នូវសាប៊ូដុសខ្លួន សាប៊ូកក់សក់ ក្រដាសអនាម័យ និងកន្សែងស្អាត | មាន-មិនមាន | ១ |
| ២-បរិវេណជុំវិញផ្ទះ | • គ្មានសម្រាមនៅបរិវេណជុំវិញផ្ទះ(ពិសេសសំរាមជាថង់ផ្លាស្ទិក) និងត្រូវមានធុងសំរាមនៅកៀ្បរផ្ទះ ឬកន្លែងទុកដាក់ | មាន-មិនមាន (*) | ១ |

| | | | |
|---|---|---|---|
| | សំរាមឲ្យបានត្រឹមត្រូវ | | |
| | • គ្មានវត្ថុដែលអាចបង្កជាជម្រកមូស | មាន-មិនមាន | ១ |
| | • រក្សាសោភ័ណភាព ដោយដាំដើមឈើ ឬដើមផ្កានានា | មាន-មិនមាន | ១ |
| ៣-ការរៀបចំអាហារ | • ផ្ទះបាយត្រូវស្អាត និងមានខ្យល់ចេញចូលគ្រប់គ្រាន់ | មាន-មិនមាន (*) | ១ |
| | • ប្រដាប់ប្រដាប្រើប្រាស់នៅផ្ទះបាយត្រូវមានលក្ខណៈល្អ ស្អាត និងរក្សានៅទីកន្លែងត្រឹមត្រូវ និងស្ងួត | មាន-មិនមាន | ១ |
| | • មិនប្រើប្រាស់ចាន កែវ ដែលប្រេះ ឬស្រាំ | មាន-មិនមាន | ១ |
| | • អ្នកចំអិនអាហារត្រូវមានអនាម័យ និងមានសំលៀកបំពាក់ត្រឹមត្រូវ | មាន-មិនមាន | ១ |
| | • ប្រើប្រាស់ សាច់ បន្លែ និងគ្រឿងផ្សំចំអិនអាហារដែលទិញក្នុងភូមិ | មាន-មិនមាន (*) | ១ |
| | • អាហារសម្រាប់ភ្ញៀវត្រូវគ្របទុកឲ្យបានត្រឹមត្រូវ និងប្រកបដោយអនាម័យល្អ | មាន-មិនមាន | ១ |
| | • ផ្តល់ទឹកស្អាតដែលមានសុវត្ថិភាពក្នុងការទទួលទានដល់ភ្ញៀវ | មាន-មិនមាន (*) | ១ |
| | • មានការផ្តល់ព័ត៌មាន និងប្រវត្តិនៃមុខម្ហូបប្រចាំថ្ងៃ | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិតៈ ៣**<br>**- ចំនួនលក្ខណវិនិច្ឆ័យៈ ១៦**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៥** | **សរុប** | **១៦** |

## ៥- សូចនាករគោលនៃសកម្មភាពកំសាន្ត

| **សូចនាករគោលនៃសកម្មភាពកំសាន្ត** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| សកម្មភាពតាមកសិដ្ឋាន និងចំការ | • មានសកម្មភាពកំសាន្តតាមកសិដ្ឋាន ចំការ វាលស្រែ និងការបង្ហាញពីធនធានធម្មជាតិនានាក្នុងភូមិ | មាន-មិនមាន | ១ |
| | • ជម្រុញឲ្យមានសកម្មភាពកំសាន្តនានា ដោយមានការចូលរួមរវាងភ្ញៀវទេសចរ និងអ្នកភូមិ | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិតៈ ១**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យៈ ២** | **សរុប** | **២** |

## ៦-សូចនាករគោលនៃសន្តិសុខសុវត្ថិភាព

| **សូចនាករគោលនៃសន្តិសុខសុវត្ថិភាព** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| សន្តិសុខសុវត្ថិភាព | • មានប្រអប់ថ្នាំសម្រាប់ព្យាបាលការឈឺថ្កាត់បឋម | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | និងមានលេខទូរស័ព្ទឡានសង្គ្រោះបន្ទាន់ ឬមន្ទីរពេទ្យដែលនៅជិត | | |
| | • អនុវត្តតាមគោលការណ៍សុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិត៖ ១**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ២** | **សរុប** | **២** |

## ៧- សូចនាករគោលនៃការផ្សព្វផ្សាយ

| **សូចនាករគោលនៃការផ្សព្វផ្សាយ** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ការផ្សព្វផ្សាយតាមអ៊ីនធឺណែត | • ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយផ្ទះស្នាក់ និងសម្រួលដល់ការកក់តាមប្រព័ន្ធអ៊ីនធឺណែត | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិត៖ ១**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១** | **សរុប** | **១** |

## ៨-សូចនាករគោលនៃគោលការណ៍និរន្តរភាព

| **សូចនាករគោលនៃគោលការណ៍និរន្តរភាព** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១-និរន្តរភាពសេដ្ឋកិច្ច | • ម្ចាស់ផ្ទះស្នាក់ត្រូវព្យាយាមទិញទំនិញ និងផលិតផលដែលផលិតក្នុងភូមិ | មាន-មិនមាន (*) | ១ |
| | • គួរជម្រុញភ្ញៀវអោយចូលរួមទិញផលិតផលក្នុងភូមិ | មាន-មិនមាន | ១ |
| ២-និរន្តរភាពបរិស្ថាន | • ហាមឃាត់ភ្ញៀវទេសចរក្នុងការចូលរួមសកម្មភាពណាដែលអាចប៉ះពាល់ដល់ធម្មជាតិ | មាន-មិនមាន (*) | ១ |
| | • ភ្ញៀវទេសចរចូលរួមក្នុងកម្មវិធីដាំដើមឈើក្នុងភូមិ កម្មវិធីសំអាតភូមិ និងសកម្មភាពនានាចូលរួមចំណែកអនុវត្តច្បាប់កិច្ចការពារបរិស្ថាន | មាន-មិនមាន | ១ |
| ៣-និរន្តរភាពនៃសង្គមវប្បធម៌ | • ជម្រាបជូនភ្ញៀវអំពីការគោរពដល់ទំនៀមទំលាប់ប្រពៃណីក្នុងសហគមន៍ និងអាកប្បកិរិយាសមរម្យ | មាន-មិនមាន | ១ |
| | • ទប់ស្កាត់រាល់អំពើទាំងឡាយណាពាក់ព័ន្ធនឹងការជួញដូរមនុស្ស គ្រឿងញៀននិងការប្រព្រឹត្តបទល្មើសទាំងឡាយណាដែលផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា | មាន-មិនមាន (*) | ១ |

| | | |
|---|---|---|
| - ចំនួនសូចនាករលំអិតៈ ៣<br>- ចំនួនលក្ខណៈវិនិច្ឆ័យៈ ៦<br>- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៣ | **សរុប** | **៦** |

## V- ស្តង់ដាផ្ទះស្នាក់ទីក្រុង

**ផ្ទះស្នាក់ទីក្រុង** គឺជាប្រភេទនៃបន្ទប់ស្នាក់នៅមួយបែបនៅតាមផ្ទះ ឬលំនៅស្ថានប្រជាពលរដ្ឋនៅក្នុងទីក្រុង ឬតាមទីប្រជុំជន ដែលម្ចាស់ផ្ទះធ្វើការរៀបចំឲ្យមានសេវាកម្មស្នាក់នៅ និងម្ហូបអាហារ *(ពិសេសអាហារពេលព្រឹក)* សម្រាប់ទទួលភ្ញៀវទេសចរមកធ្វើវិស្សមកាល ឬដំណើរទស្សនាកំសាន្តតំបន់នោះចាប់ពីមួយយប់ ឬអ្នកបំរើការស្ម័គ្រចិត្តដែលមកបំពេញភារកិច្ចលក្ខណៈបណ្តោះអាសន្ននៅក្នុងទីក្រុង ឬទីប្រជុំជន។

**ផ្ទះស្នាក់ទីក្រុង** គឺជាផ្ទះស្នាក់នៅតាមទីក្រុង ឬទីប្រជុំជន ដែលប្រជាជនអាចរៀបចំឡើងដើម្បីទទួលភ្ញៀវដោយផ្អែកលើទិដ្ឋភាព **០៣យ៉ាង គឺភាពស្អាត** (Cleanliness) **របៀបរៀបរយ** (Order Arrangement) **និងបដិសណ្ឋារកិច្ច** (Hospitality)។

ស្តង់ដាផ្ទះស្នាក់ទីក្រុងផ្តោតលើ **៧សូចនាករគោល ១៤សូចនាករលំអិត** និង **៤៧លក្ខណៈវិនិច្ឆ័យ**។

សូចនាករគោល៧រួមមាន ៖ **១- ម្ចាស់ផ្ទះស្នាក់ ២-កន្លែងស្នាក់នៅ ៣-ទីតាំង ៤-អនាម័យ និងភាពស្អាត ៥-សន្តិសុខសុវត្ថិភាព ៦-ការផ្សព្វផ្សាយ ៧- គោលការណ៍និរន្តរភាព**។

| សូចនាករគោល | សូចនាករលំអិត | លក្ខណៈវិនិច្ឆ័យ | លក្ខណៈវិនិច្ឆ័យចាំបាច់ |
|---|---|---|---|
| ១-ម្ចាស់ផ្ទះស្នាក់ | ១ | ២ | ២ |
| ២- កន្លែងស្នាក់នៅ | ៤ | ១៦ | ៦ |
| ៣- ទីតាំង | ១ | ៣ | ១ |
| ៤- អនាម័យ និងភាពស្អាត | ៣ | ១៦ | ៥ |
| ៥- សន្តិសុខសុវត្ថិភាព | ១ | ៣ | ០ |
| ៦- ការផ្សព្វផ្សាយ | ១ | ១ | ០ |
| ៧- គោលការណ៍និរន្តរភាព | ៣ | ៦ | ៣ |
| **សរុប** | **១៤** | **៤៧** | **១៧** |

### តារាងសូចនាករនៃការវាយតម្លៃផ្ទះស្នាក់ទីក្រុង ÷

### ១- សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់

| សូចនាករគោលនៃម្ចាស់ផ្ទះស្នាក់ | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| ១-ម្ចាស់ផ្ទះស្នាក់ | • អ្នកផ្តល់សេវាផ្ទះស្នាក់ទីក្រុងបានទទួលការបណ្តុះបណ្តាល | មាន-មិនមាន (*)[3] | ១ |

[3] (*)លក្ខណៈវិនិច្ឆ័យចាំបាច់

| | | | |
|---|---|---|---|
| | ស្តីពីសេវាកម្ម បដិសណ្ឋារកិច្ច និងភាសាអង់គ្លេសចាំបាច់ជាមូលដ្ឋាននានា | | |
| | • អ្នកផ្តល់សេវាផ្ទះស្នាក់ទីក្រុងត្រូវពិនិត្យសុខភាពជារៀងរាល់ ៦ខែម្តង | មាន-មិនមាន (*) | ១ |
| | **-ចំនួនសូចនាករលំអិត ៖ ១**<br>**-ចំនួនលក្ខណៈវិនិច្ឆ័យ ៖ ២**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ២** | **សរុប** | **២** |

## ២- សូចនាករគោលនៃកន្លែងស្នាក់នៅ

| **សូចនាករគោលនៃកន្លែងស្នាក់នៅ** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១-ផ្ទះ | • សំណង់ផ្ទះត្រូវរឹងមាំ និងមានលក្ខណៈសមរម្យ | មាន-មិនមាន (*) | ១ |
| | • ផ្ទះមានរបៀបរៀបរយ និងស្អាត | មាន-មិនមាន | ១ |
| | • មានបន្ទប់ភ្ញៀវយ៉ាងច្រើនចំនួន៤បន្ទប់ដោយក្នុងមួយបន្ទប់មិនលើសពី ២នាក់ | មាន-មិនមាន | ១ |
| | • មានបន្ទប់ទឹក ឬបង្គន់អនាម័យសម្រាប់ភ្ញៀវយ៉ាងតិច ០១<br>➢ ចំនួនបន្ទប់ទឹក ឬបង្គន់អនាម័យ៖ ............ | មាន-មិនមាន (*) | ១ |
| | • មានការផ្គត់ផ្គង់ថាមពលអគ្គិសនី (ការប្រើប្រាស់អាគុយ ឬថាមពលកកើតឡើងវិញជាដើម) | មាន-មិនមាន (*) | ១ |
| | • មានការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងផ្ទះគ្រប់គ្រាន់ និងគ្រប់ពេលវេលា | មាន-មិនមាន (*) | ១ |
| ២-បន្ទប់គេង | • មានការផ្គត់ផ្គង់៖ កន្ទេល តុមានថត កៅអី ឧបករណ៍សម្រាប់ផ្ទុកឥវ៉ាន់ និងព្យួរឥវ៉ាន់ដែលមានគុណភាព កញ្ចក់ មុង ឌុយភ្លើង កង្ហារ ម៉ាស៊ីនត្រជាក់<br>➢ សម្ភារបន្ទប់គេងមាន៖ ......... | មាន-មិនមាន (*) | ១ |
| | • ការតុបតែងបន្ទប់គេង និងគ្រឿងសង្ហារឹមមានលក្ខណៈសមរម្យ | មាន-មិនមាន | ១ |
| | • មានស្រោមពូក ខ្នើយកើយ ខ្នើយឱប ពូក និងកំរាលពូកមានលក្ខណៈល្អ និងស្អាតសម្រាប់ភ្ញៀវ | មាន-មិនមាន | ១ |
| | • បង្អួចមានសំណាញ់ការពារមូស | មាន-មិនមាន | ១ |
| ៣- បន្ទប់ទឹក | • បន្ទប់ងូតទឹក និងបង្គន់អនាម័យ ត្រូវមានសោរ ឬគន្លឹះឲ្យបានត្រឹមត្រូវ | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | • មានសម្ភារទាសម្រាប់ប្រើៈ ធុងសំរាម ធ្នើរ ប្រដាប់ព្យួរខ្សែង សម្ភារៈអគ្គិសនីប្រើក្នុងបន្ទប់ទឹក កន្សែងក្នុងបន្ទប់ទឹក ផាហ៊ុម កម្រាលជូតជើង សាប៊ូរាវ ប្រដាប់ដាក់សាប៊ូ និងកញ្ចក់ឆ្លុះមុខ | មាន-មិនមាន | ១ |
| ៤- ផ្ទះបាយ | • ផ្ទះត្រូវមានបន្ទប់ ឬកន្លែងរៀបចំចំអិនអាហារដាច់ដោយឡែក និងមានលក្ខណៈសមរម្យ | មាន-មិនមាន (*) | ១ |
| | • ត្រូវមានទូ ឬកន្លែងទុកដាក់សម្ភារៈចំអិនម្ហូបត្រឹមត្រូវ | មាន-មិនមាន | ១ |
| | • ត្រូវមានតុដែលមានកម្រាលជាមួយការរៀបចំជាស្រេចនូវចានសមរម្យ កន្សែងទ្រចាន និងកន្សែងទ្រាប់ដែលមានគុណភាពល្អ និងស្អាតសម្រាប់ទទួលទានអាហារ | មាន-មិនមាន | ១ |
| | • អាហារពេលព្រឹកតាមទំលាប់របស់ប្រជាជនក្នុងស្រុក ឬតាមការផ្តល់យោបល់របស់ភ្ញៀវ | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិតៈ ៤**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យៈ ១៦**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៦** | | **សរុប** | **១៦** |

## ៣- សូចនាករគោលនៃទីតាំង

| **សូចនាករគោលនៃទីតាំង** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ស្ថានភាពទីតាំងផ្ទះ | • ទីតាំងផ្ទះស្នាក់ទីក្រុងគួរទៅដល់បានតាមមធ្យោបាយណាមួយក៏បាន | មាន-មិនមាន (*) | ១ |
| | • មានទីផ្លា មានកៅអី ឬបង់ដែលអាចអង្គុយលេងបាននិងមានភ្លើងបំភ្លឺ | មាន-មិនមាន | ១ |
| | • គ្មានការរំខានដោយសំលេងខ្លាំងៗ ក្លិនមិនល្អ ហើយស្ថិតនៅមិនឆ្ងាយពីទីប្រជុំជន នៅជិតចំណតរថយន្តក្រុង ឬចំណតរថយន្តឯកជន | មាន-មិនមាន | ១ |
| - **ចំនួនសូចនាករលំអិតៈ១**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យៈ ៣**<br>- **ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ១** | | **សរុប** | **៣** |

## ៤- សូចនាករគោលនៃអនាម័យ និងភាពស្អាត

| **សូចនាករគោលនៃអនាម័យនិងភាពស្អាត** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១-ផ្ទះ (ផ្ទះបាយ បន្ទប់គេង បង្គន់ | • រាល់បន្ទប់គេង ផ្ទះបាយ និងបង្គន់ត្រូវមានធុងសំរាម និងសំអាតឲ្យបានស្អាតជានិច្ច ជៀសផុតពីធូលី និងក្លិនស្អុយ | មាន-មិនមាន (*) | ១ |

| | | | |
|---|---|---|---|
| បន្ទប់ទឹក) | • កំរាលឥដ្ឋ ឬឈើនៃផ្ទះបាយត្រូវសំអាតឲ្យបានស្អាត | មាន-មិនមាន | ១ |
| | • បន្ទប់ទឹក បង្គន់ ផ្កាឈូកងូតទឹក ត្រូវសំអាត គ្មានស្នាមប្រលាក់ ឬដុះស្លែ | មាន-មិនមាន | ១ |
| | • ប្រើថ្នាំសំលាប់មេរោគក្នុងបង្គន់ | មាន-មិនមាន | ១ |
| | • ផ្តល់នូវសាប៊ូដុសខ្លួន សាប៊ូកក់សក់ ក្រដាសអនាម័យ និងកន្សែងស្អាត | មាន-មិនមាន | ១ |
| ២-បរិវេណជុំវិញផ្ទះ | • គ្មានសម្រាមនៅបរិវេណជុំវិញផ្ទះ (ពិសេសសំរាមជាថង់ផ្លាស្ទីក) និងត្រូវទុកដាក់សម្រាមតាមការបែងចែកៈ សម្រាមកែច្នៃដាច់ដោយឡែក សម្រាមស្ងួត និងសម្រាមសើមនៅក្នុងធុងសំរាមនៅក្បែរផ្ទះឲ្យបានត្រឹមត្រូវ | មាន-មិនមាន (*) | ១ |
| | • គ្មានវត្ថុដែលអាចបង្កជាជម្រកមូស | មាន-មិនមាន | ១ |
| | • រក្សាសោភ័ណភាព ដោយដាំដើមឈើ ឬដើមផ្កានានា | មាន-មិនមាន | ១ |
| ៣-ការរៀបចំអាហារ | • ផ្ទះបាយត្រូវស្អាត និងមានខ្យល់ចេញចូលគ្រប់គ្រាន់ | មាន-មិនមាន (*) | ១ |
| | • ប្រដាប់ប្រដាប្រើប្រាស់នៅផ្ទះបាយត្រូវមានលក្ខណៈល្អ ស្អាត និងរក្សានៅទីកន្លែងត្រឹមត្រូវ និងស្ងួត | មាន-មិនមាន | ១ |
| | • មិនប្រើប្រាស់ចាន កែវ ដែលប្រេះ ឬស្រាំ | មាន-មិនមាន | ១ |
| | • អ្នកចំអិនអាហារត្រូវមានអនាម័យ និងមានសំលៀកបំពាក់ត្រឹមត្រូវ | មាន-មិនមាន | ១ |
| | • ប្រើប្រាស់ សាច់ បន្លែ និងគ្រឿងផ្សំចំអិនអាហារដែលទិញក្នុងស្រុក | មាន-មិនមាន (*) | ១ |
| | • អាហារសម្រាប់ភ្ញៀវត្រូវគ្របទុកឲ្យបានត្រឹមត្រូវ និងប្រកបដោយអនាម័យល្អ | មាន-មិនមាន | ១ |
| | • ផ្តល់ទឹកស្អាតដែលមានសុវត្ថិភាពក្នុងការទទួលទានដល់ភ្ញៀវ | មាន-មិនមាន (*) | ១ |
| | • មានការផ្តល់ព័ត៌មាន និងប្រវត្តិនៃមុខម្ហូបប្រចាំថ្ងៃ | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិតៈ ៣**<br>**- ចំនួនលក្ខណវិនិច្ឆ័យៈ ១៦**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៈ៥** | **សរុប** | **១៦** |

## ៥- សូចនាករគោលនៃសន្តិសុខសុវត្ថិភាព

| សូចនាករគោលនៃសន្តិសុខសុវត្ថិភាព | លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ | ការវាយតម្លៃ | ពិន្ទុ |
|---|---|---|---|
| សន្តិសុខសុវត្ថិភាព | • មានប្រអប់ថ្នាំសម្រាប់ព្យាបាលការឈឺថ្កាត់បឋម និងមាន | មាន-មិនមាន | ១ |

| | | | |
|---|---|---|---|
| | លេខទូរស័ព្ទឡានសង្គ្រោះបន្ទាន់ ឬមន្ទីរពេទ្យដែលនៅជិត | | |
| | • មានបំពាក់បំពង់ពន្លត់អគ្គិភ័យ | មាន-មិនមាន | ១ |
| | • អនុវត្តតាមគោលការណ៍សុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិត៖ ១**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ៣** | **សរុប** | **៣** |

## ៦- សូចនាករគោលនៃការផ្សព្វផ្សាយ

| **សូចនាករគោលនៃការផ្សព្វផ្សាយ** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ការផ្សព្វផ្សាយតាមអ៊ីនធឺណែត | • ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីផ្សព្វផ្សាយផ្ទះស្នាក់ និងសម្រួលដល់ការកក់តាមប្រព័ន្ធអ៊ីនធឺណែត | មាន-មិនមាន | ១ |
| | **- ចំនួនសូចនាករលំអិត៖ ១**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ១** | **សរុប** | **១** |

## ៧-សូចនាករគោលនៃគោលការណ៍និរន្តរភាព

| **សូចនាករគោលនៃគោលការណ៍និរន្តរភាព** | **លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ** | **ការវាយតម្លៃ** | **ពិន្ទុ** |
|---|---|---|---|
| ១- និរន្តរភាពសេដ្ឋកិច្ច | • ម្ចាស់ផ្ទះស្នាក់ត្រូវព្យាយាមទិញទំនិញ និងផលិតផលដែលផលិតក្នុងស្រុក | មាន-មិនមាន (*) | ១ |
| | • គួរជម្រុញភ្ញៀវអោយចូលរួមទិញផលិតផលក្នុងស្រុក | មាន-មិនមាន | ១ |
| ២-និរន្តរភាពបរិស្ថាន | • ហាមឃាត់ភ្ញៀវទេសចរក្នុងការចូលរួមសកម្មភាពណាដែលអាចប៉ះពាល់ដល់ធម្មជាតិ | មាន-មិនមាន (*) | ១ |
| | • ភ្ញៀវទេសចរចូលរួមក្នុងកម្មវិធីដាំដើមឈើក្នុងភូមិកម្មវិធីសំអាតភូមិ និងសកម្មភាពនានាចូលរួមចំណែកអនុវត្តច្បាប់កិច្ចការពារបរិស្ថាន | មាន-មិនមាន | ១ |
| ៣-និរន្តរភាពនៃសង្គមវប្បធម៌ | • ជម្រាបជូនភ្ញៀវអំពីការគោរពដល់ទំនៀមទំលាប់ប្រពណីក្នុងសហគមន៍ និងអាកប្បកិរិយាសមរម្យ | មាន-មិនមាន | ១ |
| | • ទប់ស្កាត់រាល់អំពើទាំងឡាយណាពាក់ព័ន្ធនឹងការជួញដូរមនុស្ស គ្រឿងញៀន និងការប្រព្រឹត្តបទល្មើសទាំងឡាយណាដែលផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា | មាន-មិនមាន (*) | ១ |
| | **- ចំនួនសូចនាករលំអិត៖ ៣**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យ៖ ៦**<br>**- ចំនួនលក្ខណៈវិនិច្ឆ័យចាំបាច់ ៖ ៣** | **សរុប** | **៦** |

## VI- យន្តការនៃការវាយតម្លៃស្តង់ដាផ្ទះស្នាក់សហគមន៍ ស្តង់ដាផ្ទះស្នាក់ជនបទ និងស្តង់ដាផ្ទះស្នាក់ទីក្រុង

តារាងវាយតម្លៃនឹងអនុញ្ញាតឲ្យធ្វើការផ្តល់ពិន្ទុដល់ផ្ទះស្នាក់សហគមន៍ (៩៣លក្ខណៈវិនិច្ឆ័យស្មើនឹង៩៣ពិន្ទុសរុប) ផ្ទះស្នាក់ជនបទ (៤៤លក្ខណៈវិនិច្ឆ័យស្មើនឹង៤៤ពិន្ទុសរុប) និងផ្ទះស្នាក់ទីក្រុង (៤៧លក្ខណៈវិនិច្ឆ័យស្មើនឹង៤៧ពិន្ទុសរុប)។

- ឡាបិល ផ្ទះស្នាក់សហគមន៍នឹងផ្តល់ជូនផ្ទះស្នាក់ណាដែលទទួលបានពិន្ទុស្មើនឹង ៦០% នៃចំនួនពិន្ទុសរុប (ចំនួន ៥៦លក្ខណៈវិនិច្ឆ័យ នៃលក្ខណៈវិនិច្ឆ័យសរុប)។
- ឡាបិល ផ្ទះស្នាក់ជនបទទនឹងនឹងផ្តល់ជូនផ្ទះស្នាក់ណាដែលទទួលបានពិន្ទុស្មើនឹង ៦០% នៃចំនួនពិន្ទុសរុប (ចំនួន ២៦លក្ខណៈវិនិច្ឆ័យ នៃលក្ខណៈវិនិច្ឆ័យសរុប)។
- ឡាបិល ផ្ទះស្នាក់ទីក្រុងនឹងផ្តល់ជូនផ្ទះស្នាក់ណាដែលទទួលបានពិន្ទុស្មើនឹង ៦០% នៃចំនួនពិន្ទុសរុប (ចំនួន ២៨លក្ខណៈវិនិច្ឆ័យនៃលក្ខណៈវិនិច្ឆ័យសរុប)។
- ឡាបិល ផ្ទះស្នាក់កម្ពុជាមានសុពលភាពរយៈពេល**៣ ឆ្នាំ** ។

## VII-ដំណើរការនៃការប្រឡងប្រណាំង

- **ដំណាក់កាលទី១៖** ផ្ទះស្នាក់ទាំងអស់អាចចូលរួមការប្រលងប្រណាំងដោយស្ម័គ្រចិត្ត។
- **ដំណាក់កាលទី២៖** ការវាយតម្លៃបឋមដោយម្ចាស់ផ្ទះស្នាក់ខ្លួនឯងផ្ទាល់ (self-assessment audit check) មុនពេលធ្វើការដាក់ពាក្យស្នើសុំមកកាន់អគ្គនាយកដ្ឋានទេសចរណ៍របស់ក្រសួងទេសចរណ៍។
- **ដំណាក់កាលទី៣៖** ការដាក់ពាក្យស្នើសុំរបស់ម្ចាស់ផ្ទះស្នាក់មកកាន់អគ្គនាយកដ្ឋានទេសចរណ៍របស់ក្រសួងទេសចរណ៍ដោយមានភ្ជាប់មកជាមួយនូវឯកសារវាយតម្លៃបឋមរបស់ម្ចាស់ផ្ទះស្នាក់។
- **ដំណាក់កាលទី៤៖** បន្ទាប់ពីបានទទួលពាក្យស្នើសុំរបស់ម្ចាស់ផ្ទះស្នាក់ ក្រុមការងារវាយតម្លៃផ្ទះស្នាក់របស់ក្រសួងទេសចរណ៍ នឹងចុះត្រួតពិនិត្យវាយតម្លៃដល់ទីតាំងផ្ទះស្នាក់។
- **ដំណាក់កាលទី៥៖** របាយការណ៍ស្តីពីលទ្ធផលចុះត្រួតពិនិត្យវាយតម្លៃផ្ទះស្នាក់របស់ក្រុមការងារក្រសួងទេសចរណ៍លើផ្ទះស្នាក់។
- **ដំណាក់កាលទី៦៖** ការផ្តល់ឡាបែលដល់ម្ចាស់ផ្ទះស្នាក់។

* **<u>បញ្ជាក់៖</u>** ម្ចាស់ផ្ទះស្នាក់ មិនតម្រូវឲ្យមានការបង់កម្រៃសេវាសម្រាប់ការស្នើសុំឡាបិលផ្ទះស្នាក់កម្ពុជានោះទេ។

# ឧបសម្ព័ន្ធនៃប្រកាស លេខ ១៣៣. ប្រក. ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥

# ស្ដីពី

# “ការអនុវត្តស្តង់ដាផ្ទះស្នាក់កម្ពុជា”

# (Cambodia Homestay Standard)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៣៣ ប.ក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៥

## ប្រកាស
## ស្តីពី
## ការអនុវត្តស្តង់ដាផ្ទះស្នាក់កម្ពុជា

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៩៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹតលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍។

## សម្រេច

**ប្រការ ១._**

ប្រកាសនេះ មានគោលបំណងដាក់ឱ្យប្រើប្រាស់ក្នុងវិស័យទេសចរណ៍នូវស្តង់ដាផ្ទះស្នាក់កម្ពុជាដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

ស្តង់ដានេះត្រូវបានប្រើប្រាស់ សំដៅពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់ និងដើម្បីឱ្យម្ចាស់ផ្ទះស្នាក់កម្ពុជាអាចអភិវឌ្ឍសេវាកម្មផ្ទះស្នាក់ប្រកបដោយសុវត្ថិភាព គុណភាព សុខដុមរមនា និងសេចក្តីថ្លៃថ្នូរ រួមចំណែកក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ប្រកបដោយចិរភាព គុណភាព និងការទទួលខុសត្រូវ។

**ប្រការ ២._**

ដើម្បីឱ្យម្ចាស់ផ្ទះស្នាក់ទទួលបាននូវចំណេះដឹងរៀបចំអភិវឌ្ឍន៍ផ្ទះស្នាក់ និងអនុវត្តតាមលក្ខណវិនិច្ឆ័យ ដូចមានកំណត់ក្នុងស្តង់ដាផ្ទះស្នាក់កម្ពុជា ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អង្គការ មន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវចូលរួមគាំទ្រ និងជំរុញការអនុវត្តស្តង់ដាផ្ទះស្នាក់កម្ពុជា។

**ប្រការ ៣._**

ស្តង់ដាផ្ទះស្នាក់កម្ពុជានេះ អាចនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មដោយក្រសួងទេសចរណ៍ក្នុងករណីចាំបាច់។

**ប្រការ ៤._**

ម្ចាស់ផ្ទះស្នាក់ មិនតម្រូវឱ្យមានការបង់កម្រៃសេវាសម្រាប់ការស្នើសុំឡាបិលផ្ទះស្នាក់កម្ពុជានោះទេ។

**ប្រការ ៥._**

រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នាយកខុទ្ទកាល័យ គ្រប់ប្រធាននាយកដ្ឋាន ប្រធានក្រុមអ្នកច្បាប់ អធិការ ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលអនុវត្តតាមសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**__កន្លែងទទួល:__**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលារាជធានី-ខេត្ត
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  "ដើម្បីជ្រាប"
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ១

## វាក្យស័ព្ទ និងនិយមន័យ

ដែលបានកំណត់នៅក្នុងស្តង់ដាផ្ទះស្នាក់កម្ពុជារួមមាន៖

១- **រមណីយដ្ឋានទេសចរណ៍៖** សំដៅដល់ទីតាំង ដែលមានភាពទាក់ទាញទេសចរដូចជា វប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬដែលរៀបចំកែច្នៃឡើង ហើយត្រូវបានអនុញ្ញាតឱ្យរៀបចំសម្រាប់ធ្វើអាជីវកម្ម បម្រើឱ្យការសម្រាកលំហែ និងកម្សាន្តតាមគោលបំណងទេសចរណ៍ស្របច្បាប់។

២- **ភាពមានលក្ខណៈដើម៖** ភាពពិតប្រាកដ មិនក្លែងបន្លំ ឬភាពត្រឹមត្រូវ ដើម្បីផ្តល់ជូនភ្ញៀវនូវបទពិសោធន៍ដ៏ត្រឹមត្រូវ ពិសេសទាក់ទងទៅនឹងធម្មជាតិ និងវប្បធម៌ក្នុងស្រុក។

៣- **ការសង្គ្រោះបន្ទាន់បឋម៖** ការសង្គ្រោះបន្ទាន់ និងការព្យាបាលជាបឋម ក្នុងករណីដែលភ្ញៀវមានរបួសស្នាមបន្តិចបន្តួច ឬឈឺមុនពេលភ្ញៀវទទួលបានការព្យាបាលសមរម្យពេលទៅដល់មន្ទីរពេទ្យ។

៤- **ជីវចំរុះ៖** ប្រភេទសត្វ និងរុក្ខជាតិច្រើនប្រភេទដែលមាននៅក្នុងបរិស្ថានធម្មជាតិ។

៥- **ការកក់ទុកមុន៖** ការកក់ទុកមុនសម្រាប់សេវាផ្ទះស្នាក់ តាមរយៈមធ្យោបាយទំនាក់ទំនងរួមមាន៖ អ៊ីម៉ែល អ៊ីនធឺណែត ទូរស័ព្ទ ឬទូរសារ។ល។

៦- **ក្រមប្រតិបត្តិ៖** ជាការរៀបរៀងនូវគោលការណ៍ និងវិន័យ ដើម្បីកំណត់ការទទួលខុសត្រូវ ឬប្រកាន់អាកប្បកិរិយាសមរម្យរបស់ភ្ញៀវ និងម្ចាស់ផ្ទះស្នាក់។ ការរៀបចំឱ្យមានឯកសារស្តីពី **"គួរធ្វើ និងមិនគួរធ្វើ"** (Dos and Don'ts) ដើម្បីរក្សានូវការគោរពដល់ទំនៀមទំលាប់ប្រពៃណីនៅតាមសហគមន៍ផ្ទះស្នាក់។

៧- **មជ្ឈមណ្ឌលសហគមន៍៖** គឺជាកន្លែងសម្រាប់សកម្មភាពសហគមន៍ដូចជា ការស្វាគមន៍ពេលភ្ញៀវមកដល់ ការសម្តែងសិល្បៈ ការដាក់តាំងបង្ហាញវត្ថុសិល្បៈ ឬសកម្មភាពសង្គមនានា។

៨- **ការបណ្តុះបណ្តាលពីសហគមន៍មួយទៅសហគមន៍មួយទៀត៖** កម្មវិធីបណ្តុះបណ្តាលត្រូវរៀបចំឡើងដោយការធ្វើដំណើរទស្សនកិច្ចសិក្សាស្វែងយល់ផ្លាស់ប្តូរបទពិសោធន៍ពីសហគមន៍ផ្ទះស្នាក់ ដែលទទួលបានជោគជ័យ និងបង្កើតឱ្យមានទំនាក់ទំនងដើម្បីអភិវឌ្ឍន៍ផ្ទះស្នាក់។

៩- **ជំនាញក្នុងការបកស្រាយ៖** ការយល់ដឹងដែលរួមបញ្ចូលនូវសមត្ថភាពជាច្រើន មិនមែនត្រឹមតែសមត្ថភាពភាសាទេ ប៉ុន្តែធ្វើការបកស្រាយប្រកបដោយប្រសិទ្ធភាព។

១០- **ថ្លៃកញ្ចប់សេវា៖** ជាការដាក់តម្លៃនៃសេវារួមបញ្ចូលគ្នា ដើម្បីសម្រួលដល់ភ្ញៀវក្នុងការជ្រើសរើសយកកញ្ចប់សេវា និងអាចរីករាយជាមួយសកម្មភាពទាំងនោះ។ ជាទូទៅកញ្ចប់សេវារួមមាន៖ ការដឹកជញ្ជូន ការស្នាក់នៅ អាហារ ដំណើរកំសាន្ត និងសកម្មភាពផ្សេងៗ។

១១- **ប្រព័ន្ធកក់ទុកមុន៖** ជាប្រព័ន្ធដែលអាចឱ្យភ្ញៀវធ្វើការកក់មុនសម្រាប់ទិញកញ្ចប់សេវាផ្ទះស្នាក់ តាមរយៈការកក់តាមប្រព័ន្ធអ៊ីធឺណែត ឬទូរស័ព្ទ។

១២- **ចំណុចពិសេសក្នុងការលក់៖** ភាពទាក់ទាញពិសេស ឬប្លែកនៃសេវាស្នាក់នៅភូមិដែលខុសប្លែកពីភូមិដ៏ទៃ និងជាកត្តាចម្បងក្នុងការទាក់ទាញភ្ញៀវ។

១៣- **សូចនាករ៖** គឺជាបណ្តុះនៃការកម្រិតគុណភាព ឬបរិមាណ ដែលការវាយតម្លៃនឹងត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ។

# ឧបសម្ព័ន្ធ ២

## លក្ខខណ្ឌក្នុងការចូលរួមកម្មវិធី

## ស្តង់ដាផ្ទះស្នាក់កម្ពុជា

ដើម្បីអាចស្នើសុំឡាបិលផ្ទះស្នាក់កម្ពុជា ម្ចាស់ផ្ទះស្នាក់ចាំបាច់ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

**១- ផ្ទះស្នាក់សហគមន៍**

| | **លក្ខខណ្ឌ** | |
|---|---|---|
| ១ | យ៉ាងហោចណាស់មានអ្នកចុះឈ្មោះផ្តល់សេវាផ្ទះស្នាក់ចំនួន៥នៅក្នុងភូមិ | |
| ២ | អ្នកផ្តល់សេវាផ្ទះស្នាក់មិនធ្លាប់មានពាក់ព័ន្ធនឹងបទឧក្រិដ្ឋ | |
| ៣ | អ្នកផ្តល់សេវាផ្ទះស្នាក់មានសុខភាពល្អ | |

*__បញ្ជាក់៖__ សហគមន៍នឹងទទួលបានបណ្ណសរសើរចេញដោយក្រសួងទេសចរណ៍ ក្នុងករណីដែលមានផ្ទះលើសពី ០៥ ទទួលបានឡាបិលផ្ទះស្នាក់កម្ពុជា។

**២- ផ្ទះស្នាក់ជនបទ**

| | **លក្ខខណ្ឌ** | |
|---|---|---|
| ១ | អ្នកផ្តល់សេវាផ្ទះស្នាក់មិនធ្លាប់មានពាក់ព័ន្ធនឹងបទឧក្រិដ្ឋ | |
| ២ | អ្នកផ្តល់សេវាផ្ទះស្នាក់មានសុខភាពល្អ | |

**៣- ផ្ទះស្នាក់ទីក្រុង**

| | **លក្ខខណ្ឌ** | |
|---|---|---|
| ១ | អ្នកផ្តល់សេវាផ្ទះស្នាក់មិនធ្លាប់មានពាក់ព័ន្ធនឹងបទឧក្រិដ្ឋ | |
| ២ | អ្នកផ្តល់សេវាផ្ទះស្នាក់មានសុខភាពល្អ | |




ដីឡូតិ៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤
E-mail: adimin@mot.gov.kh Website: www.mot.kh